# បទសម្ភាសន៍ជាមួយ ជុំ ម៉ី ដើមបណ្តឹងរដ្ឋប្បវេណី

*ដោយ ម៉ៃខល សាលីបា*

***ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩***

*ប្រែសម្រួលដោយ ទែន សុខស្រីនិត និង វ៉ាន់ថាន់ ពៅដារ៉ា*

*លោកអ៊ុំ ជុំ ម៉ី គឺជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនៅក្នុងការជំនុំជម្រះសេចក្តីលើសំណុំរឿងប្រឆាំងនឹង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) និងជាអ្នករស់រានមានជីវិតមួយរូបពីគុកទួលស្លែង (មន្ទីរស-២១) ។ នាពេលថ្មីៗនេះ លោកអ៊ុំត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធាន «សហគមន៍ជនរងគ្រោះនៃរបបខ្មែរក្រហម» ដែលទើបតែបង្កើតឡើង ហើយក៏ជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូបក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ដែលចូលរួមនៅក្នុងគ្រប់សវនាការជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច ។ នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៩ លោកអ៊ុំបានជួបជាមួយនឹងមន្ត្រី ដែលធ្វើការឲ្យគេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហមនៅកម្ពុជាដែលហៅកាត់ថា ស៊ី.ធី.អ៊ឹម នៅឯគុកទួលស្លែង ដើម្បីពិភាក្សាអំពីបទពិសោធន៍ និងទស្សនៈរបស់លោកអ៊ុំអំពីការជំនុំជម្រះសេចក្តីប្រឆាំងនឹង ឌុច ។*

***ស៊ី.ធី.អ៊ឹម ៖*** *តើលោកអ៊ុំបានស្ថិតនៅក្រោមការឃុំឃាំងនៅមន្ទីរស-២១អស់រយៈពេលប៉ុន្មាន? តើលោកអ៊ុំអាចរៀបរាប់ពីដំណើរជីវិតរបស់លោកអ៊ុំនៅក្នុងគុកនោះបានដែរឬទេ?*

***ជុំ ម៉ី៖*** *ខ្ញុំជាប់ឃុំឃាំងអស់រយៈពេលបួនខែ ។ ក្នុងអំឡុងពេលនោះ ខ្ញុំត្រូវបានគេដាក់ខ្នោះជើងជាប់នឹងឥដ្ឋ និងចងមុខនៅក្នុងបន្ទប់ឃុំខ្លួនដែលធ្វើពីឥដ្ឋមានប្រវែងបណ្តោយពីរម៉ែត្រ និងទទឹងមួយម៉ែត្រ ។ ខ្ញុំដេកផ្ងៀងខ្លួន ពីព្រោះថាខ្នងរបស់ខ្ញុំមានការឈឺចាប់ ។ ខ្ញុំត្រូវប្រុងប្រយ័ត្នដោយមិនហ៊ានកម្រើកខ្លួនទេ ពីព្រោះថាប្រសិនបើអ្នកយាមឮសំឡេងច្រវ៉ាក់ ពួកវានឹងវាយខ្ញុំ ២០០រំពាត់ ដើម្បីជាការដាក់ទណ្ឌកម្មសម្រាប់ការកម្រើកខ្លួនដោយគ្មានការអនុញ្ញាត ។ ខ្ញុំបានទទួលរងនូវការធ្វើទារុណកម្មក្នុងពេលសួរចម្លើយ ។ ក្រចកជើងរបស់ខ្ញុំត្រូវបានដកចេញដោយដង្កាប់ ។ ខ្ញុំបានទទួលរងនូវការឆក់នឹងចរន្តអគ្គិសនីជាច្រើនដង ដែលធ្វើឲ្យត្រចៀកម្ខាងរបស់ខ្ញុំមិនអាចស្តាប់ឮរហូតមកសព្វថ្ងៃនេះ ។ ខ្ញុំបានទទួលរងនូវការវាយនឹងរំពាត់ ហើយម្រាមដៃរបស់ខ្ញុំខ្លះបានបាក់ ។ ក្រោយពីការសួរចម្លើយ ខ្ញុំត្រូវបានបញ្ជូនមកកាន់បន្ទប់ឃុំខ្លួនវិញ*

ហើយខ្ញុំអាចត្រឹមតែយំខ្សឹបខ្សួលយ៉ាងស្ងៀមស្ងាត់ ពីព្រោះថា អ្នកទោសទាំងអស់មិនអនុញ្ញាតឲ្យបង្កជាសំឡេងរំខានអ្វីនៅក្នុងគុកឡើយ ។

**ស៊ី.ធី.អ៊ឹម:** ក្នុងចំណោមអ្នកទោសដែលបានប៉ាន់ស្មានថាមានចំនួន ១៤.០០០នាក់ នៅគុកទួលស្លែង ហើយមានតែអ្នកទោសចំនួន១៧នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។ តើលោកអ៊ំអាចរស់នៅរបៀបណា បើអ្នកទោសទាំងអស់ដែលនៅជុំវិញលោកអ៊ំសុទ្ធតែត្រូវបានសម្លាប់ចោល?

**ជុំ ម៉ី:** នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញដំបូង កងទ័ពទាំងនោះមិនស្គាល់មន្ទីរ ស-២១ទេ ។ អ្នកយាមគុកបានជម្លៀសអ្នកទោសចេញ ហើយដំបូងខ្ញុំត្រូវបានគេបញ្ជូនទៅជំរុំកសាងខ្លួនព្រៃស (មន្ទីរស-២៤) ។ នៅទីនោះ ខ្ញុំបានរកឃើញប្រពន្ធរបស់ខ្ញុំដែលជាប់ឃុំនៅមន្ទីរស-២៤ ហើយគាត់បង្កើតបានកូនប្រុសមួយ ។ ខ្ញុំបានបីកូនប្រុសរបស់ខ្ញុំនៅនឹងដៃជាលើកដំបូង ខណៈពេលដែលយើងបន្តរត់ភៀសខ្លួនចេញពីទីក្រុង ។ ក្រុមអ្នកភៀសខ្លួនបានទទួលរងនូវការបាញ់ប្រហារពីកងទ័ពវៀតណាម ហើយចុងក្រោយក៏បានមកដល់វត្តមួយដែលមានកម្មាភិបាលខ្មែរក្រហមនៅទីនោះយ៉ាងកកកុញ ។ ក្រោយនោះមួយយប់ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យសម្លាប់គ្រួសាររបស់ខ្ញុំ ។ ក្នុងការបាញ់រះដោយកាំភ្លើងជាច្រើន ប្រពន្ធនិងកូនប្រុសរបស់ខ្ញុំបានត្រូវគ្រាប់កាំភ្លើងស្លាប់ ចំណែកខ្ញុំវិញបានរត់រួចខ្លួន ។ ខ្ញុំបានគេចចូលទៅលាក់ខ្លួនក្នុងព្រៃតែម្នាក់ឯង ។ ខ្ញុំបានលាក់ខ្លួនក្នុងព្រៃនៅពេលថ្ងៃ និងប្រថុយចេញមកខាងក្រៅនៅពេលយប់តែប៉ុណ្ណោះ ។ ខ្ញុំបានលាក់ខ្លួនក្នុងព្រៃអស់រយៈពេលជាច្រើនថ្ងៃ និងយប់ដោយគ្មាន ទឹក និងអាហារឡើយ មុននឹងអាចស្វែងរកផ្លូវវិលត្រឡប់មកកាន់ទីក្រុងវិញ ។

**ស៊ី.ធី.អ៊ឹម:** លោកអ៊ំបានមកកាន់គុកទួលស្លែងនេះញឹកញាប់គួរសម ។ បើយោងតាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកអ៊ំ តើអ្វីដែលជំរុញឲ្យលោកអ៊ំវិលត្រឡប់មកកាន់ទីកន្លែងដែលពោរពេញដោយភាពភ័យខ្លាចនេះទៅវិញ?

**ជុំ ម៉ី:** ខ្ញុំមកគុកទួលស្លែងជារៀងរាល់ថ្ងៃ លើកលែងតែថ្ងៃណាដែលខ្ញុំចូលរួមសវនាការកាត់ទោសឌុច ឬខ្ញុំទៅខេត្តប៉ុណ្ណោះ ។ ខ្ញុំមកកាន់ទីកន្លែងនេះជារៀងរាល់ថ្ងៃដើម្បីប្រាប់ការពិតដល់ពិភពលោកអំពីគុកទួលស្លែង ។ ខ្ញុំបាននិយាយជាមួយភ្ញៀវគ្រប់ជាតិសាសន៍ទាំងអស់ ។ ខ្ញុំគិតថា

វាពិតជាមានសារសំខាន់ក្នុងការបង្ហាញពីការពិតអំពីគុកនេះ មិនត្រឹមតែឲ្យដល់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យដល់សហគមន៍អន្តរជាតិទាំងមូល ដើម្បីកុំឲ្យឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងនេះកើតឡើងសារជាថ្មីម្តងទៀតនៅក្នុងពិភពលោក ។

**ស៊ី.ធី.អ៊ឹម៖** ថ្មីៗកន្លងទៅនេះ មេធាវីការពារក្តីបានបញ្ចាំងខ្សែវីឌីអូអំពីការសុំទោសរបស់ ឌុច ចំពោះជនរងគ្រោះនៅមន្ទីរស-២១ ដែលលោកអ៊ំបានអរគុណ ឌុច សម្រាប់ការទទួលស្គាល់កំហុសរបស់ខ្លួន ។ ជាមួយនឹងការខិតជិតមកដល់នៃសេចក្តីសម្រេចរបស់តុលាការ តាំងពីការចាប់ផ្តើមដំបូងនៃការកាត់ទោសមក តើទស្សនៈរបស់លោកអ៊ំមានចំពោះឌុច បានផ្លាស់ប្តូរដែរឬទេ?

**ជុំ ម៉ី៖** មុនដំបូង ខ្ញុំបានត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយកសំណើរសុំការអត់ឱនទោសរបស់ ឌុច ពីព្រោះខ្ញុំបានគិតថា ការសុំទោសរបស់ ឌុច មានភាពស្មោះត្រង់ និងគ្មានលក្ខខណ្ឌអ្វីទាំងអស់ ។ ប៉ុន្តែក្នុងអំឡុងពេលដំណើរការជំនុំជម្រះសេចក្តី ឌុច បានបដិសេធចំពោះសក្ខីកម្មជាច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ទោះបីជា ឌុច មានភាពស្មោះត្រង់ចំពោះព្រឹត្តិការណ៍ជាច្រើនដែលបានកើតឡើងក៏ដោយ ឌុច បានបង្ហាញឲ្យឃើញថាខ្លួនគាត់ កំពុងតែថ្លឹងថ្លែងមើលយ៉ាងល្អិតល្អន់ដែលជាញឹកញាប់ជ្រើសរើសអ្វីយកមកនិយាយ ដោយផ្អែកលើអ្វីដែលខ្លួនគាត់គិតថាមានប្រយោជន៍ខ្លាំងសម្រាប់ខ្លួនឯង ។ សម្រាប់ហេតុផលនេះ ទស្សនៈរបស់ខ្ញុំបានផ្លាស់ប្តូរ ដែលកាលពីមុនដំបូង ខ្ញុំត្រៀមខ្លួនដើម្បីទទួលយកការសុំទោសរបស់ ឌុច ប៉ុន្តែខ្ញុំនឹងមិនត្រៀមខ្លួនដើម្បីទទួលយកការសុំទោសរបស់ ឌុច ទៀតទេ ប្រសិនបើ ឌុច នៅតែបន្តបដិសេធចំពោះសក្ខីកម្មសំខាន់ៗជាច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ។

**ស៊ី.ធី.អ៊ឹម៖** អង្គជំនុំជម្រះបានហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណី មិនឲ្យសួរសំណួរទៅកាន់សាក្សីអត្តចារិក ដែលបង្កឲ្យមានការធ្វើពហិការរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ប្រសិនបើលោកអ៊ំអាចជួបតទល់ជាមួយ ឌុច ទាក់ទិននឹងបញ្ហានេះ តើលោកអ៊ំនឹងសួរសំណួរអ្វីខ្លះទៅកាន់ឌុច?

**ជុំ ម៉ី៖** ជាដំបូង ខ្ញុំចង់និយាយថា ប្រសិនបើសេចក្តីសម្រេចរបស់តុលាការពិតជាមិនមានយុត្តិធម៌ ហើយខ្ញុំនៅតែមិនយល់ច្បាស់អំពីហេតុផលរបស់តុលាការ ។ តុលាការបានអនុញ្ញាតឲ្យសិស្ស

និងគ្រូបង្រៀនធ្វើសក្ខីកម្មស្តីពីអំពើដែល ឌុច បានធ្វើពីមុន និងក្រោយពេលដែល ឌុច ក្លាយជាប្រធានមន្ទីរស-២១ ។ តាមទស្សនៈរបស់ខ្ញុំ សក្ខីកម្មបែបនេះគឺមិនមានជាប់ពាក់ព័ន្ធអ្វីឡើយ ។ នៅពេលដែលឡើងធ្វើសក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគ្រើនរំឭកជារឿយៗថា សូមនិយាយត្រឹមតែអំពីព្រឹត្តិការណ៍ ដែលកើតឡើងក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ បានហើយ ។ ប្រសិនបើខ្ញុំបានដឹងអំពីដំណើរការតាំងពីដំបូង ដែលរារាំងយើងមិនឲ្យចូលរួមពេញលេញក្នុងដំណើរការនីតិវិធីនោះ ម្ល៉េះខ្ញុំនឹងមិនដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ។ ខ្ញុំចង់ដឹងថា តើមាននរណាផ្សេងដែលនៅពីក្រោយ ឌុច? តើ ឌុច បានទទួលបញ្ជាផ្ទាល់ឲ្យសម្លាប់ ឬការសម្លាប់នោះគឺជាគំនិតរបស់ ឌុច? ខ្ញុំក៏ចង់ដឹងថាហេតុអ្វីបានជា ឌុច និយាយតែពីជនរងគ្រោះដែលស្លាប់ហើយ និងមិនដែលនិយាយលើកឡើងពីអ្នករស់រានមានជីវិតពីមន្ទីរស-២១ និងពីរបបខ្មែរក្រហមសោះអីចឹង ។

**ស៊ី.ធី.អ៊ឹម:** ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងក៏បានហាមប្រាមមិនឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានអំពីការសម្រេចសេចក្តីលើទោសទណ្ឌ ។ តើលោកអ៊ំគិតថា ឌុច គួរត្រូវបានកាត់ទោសយ៉ាងដូចម្តេចទៅវិញ?

**ជុំ ម៉ី:** ខ្ញុំចង់ឲ្យតុលាការសម្រេចបានយុត្តិធម៌សម្រាប់ភាគីទាំងអស់ ដែលបានចូលរួមក្នុងដំណើរការជំនុំជម្រះនេះ ។ ខ្ញុំមិនគិតថា ឌុច នឹងត្រូវទទួលបានការកាត់ទោសអតិបរិមាឲ្យជាប់ពន្ធនាគារអស់មួយជីវិតនោះទេ ។ ឌុច មិនមែនជាសត្វធាតុទេ ហើយ ឌុច នៅតែជាមនុស្សម្នាក់ដែលគេព្រមទាំងបានសារភាពកំហុស និងទទួលស្គាល់ឧក្រិដ្ឋកម្មជាច្រើនរបស់ខ្លួន ។ បើទោះបីជាត្រូវសម្លាប់ ឌុច ក៏ដោយ ក៏នៅតែមិនអាចសងជីវិតមនុស្សចំនួន១៦.០០០នាក់ ដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ វិញបានដែរ ។

**ស៊ី.ធី.អ៊ឹម:** តើការចូលរួមរបស់លោកអ៊ំនៅក្នុងតុលាការបានជួយឲ្យការឈឺចាប់ និងទុក្ខលំបាកផ្សេងៗស្រាកស្រានខ្លះដែរឬទេ ពីព្រោះលោកអ៊ំមានអារម្មណ៍ថា យុត្តិធម៌អាចនឹងសម្រេចបាន ឬអាចនឹងបង្កើនឡើងបាន ដោយសារតែយុត្តិធម៌នេះធ្វើឲ្យការចងចាំដ៏ឈឺផ្សារស់ឡើងវិញ?

**ជុំ ម៉ី៖** ជាការពិត ការឈឺចាប់គឺស្ថិតនៅជាប់ក្នុងក្រអៅបេះដូងរបស់ខ្ញុំ នៅពេលដែលខ្ញុំចូលរួមក្នុងសវនាការជំនុំជម្រះសេចក្តី និងស្តាប់ឮសក្ខីកម្មរៀបរាប់ពីព្រឹត្តិការណ៍សោកនាដកម្មដែលបានកើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហម ។ យ៉ាងណាមិញ ខ្ញុំបានចូលរួមក្នុងសវនាការជំនុំជម្រះជារៀងរាល់ថ្ងៃ ដែលញ៉ាំងឲ្យចៅក្រម និង ឌុច អាចមើលឃើញនូវក្រសែភ្នែករបស់ខ្ញុំដោយផ្ទាល់ ហើយមើលឃើញនូវភាពឈឺចាប់ និងទុក្ខវេទនាដែលខ្ញុំបានទទួលរង ។ ជាងនេះទៅទៀត ខ្ញុំបានចូលរួមក្នុងសវនាការជំនុំជម្រះជារៀងរាល់ថ្ងៃដែលញ៉ាំងឲ្យខ្ញុំអាចតាមដានអ្វីៗទាំងអស់ដែលកើតមានឡើងនៅទីនោះ ។ វាពិតជាមានសារសំខាន់ដែលថាការជំនុំជម្រះសេចក្តីសម្រេចបាននូវយុត្តិធម៌ មិនមែនសម្រាប់តែប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ពិភពលោកទាំងមូលទៀតផង ។